## ឧបសម្ព័ន្ធទី ៩: ចំណង់ចំណូលចិត្តរបស់កសិករក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំ

| ចំនាត់ថ្នាក់ | ប្រភេទនិងទីតាំងដំណាំ | លក្ខណៈសម្បត្តិ | កំណត់ត្រានូវសេចក្តីពន្យល់ |
|---|---|---|---|
| ១ | ដំនាំឈើហូបផ្លែនៅក្នុងសួនច្បារនិងតាមបណ្តោយព្រំដី | *កន្ទ្បោមស្លឹក:* ក្រាស់បង្គួរ អង្កត់ផ្ចិតមធ្យម មែកកែងនឹងដើមច្រើន<br>*ដើម:* ត្រង់ស្រឡូន វែង (កាន់តែវែងកាន់តែល្អ សំរាប់ការផលិតឈើហ៊ុប ដែលមានគុណភាពល្អ និងតំលៃខ្ពស់)<br>*របៀបចាក់ឫស:* ឫសចំហៀងចាក់ជ្រៅទៅក្នុងដីពីជំរៅមិនតិចជាង ១-៣ ហ្វីត ។<br>*របៀបចេញផ្លែផ្កា:* ផ្លែជាប់នឹងដើមឬមែកសំរាប់ផ្លែខ្នុរ ផ្លែជាប់នឹងមែកសំរាប់ផ្លែស្វាយ ។ល ។ | ការប្រើប្រាស់លំហផ្ទៃដីឱ្យមានប្រសិទ្ធិភាពគឺជាអាទិភាពចំបងនៃការលាយចំរុះប្រភេទដំណាំនៅក្នុងសួនច្បារ ។ ការងារនេះមានសារៈសំខាន់ផងដែរសំរាប់ស្រ្តីនៃគ្រួសារដែលគ្មានដី ឬ បណ្តាអ្នកកាន់កាប់ដីតូចតាច ។ លក្ខណៈ សម្បត្តិរបៀបនេះ ធានានូវភាពសំបូរនៃផ្លែ កាត់បន្ថយ ក៏រិតម្លប់ ប្រើប្រាស់ដោយមានប្រសិទ្ធិភាពនូវសារធាតុចិញ្ចឹមដែលនៅក្នុងដីដ៏ជ្រៅ និងរក្សាទុកនូវលំហនៅស្រទាប់ក្រោមមួយចំនួនសំរាប់ដាំដំណាំឆ្លាស់ផងដែរ ។ ដើមឈើហូបផ្លែអាចលក់ជាឈើសំណង់នៅពេលដែលចាស់ ។ របៀបផ្តល់ផ្លែផ្កា សង្ឃឹមថាដូចលក្ខខ័ណ្ឌធម្មតានៃប្រភេទឈើនិមួយៗ ។ ប៉ុន្តែអ្នកខ្លះចង់ឱ្យមានផ្លែនៅតែនឹងមែកព្រោះខ្លាចចោរលួចហើយអ្នកខ្លះទៀតចង់បានផ្លែ ស្វាយផ្លែជាប់នឹងដើមដូចខ្នុរដែរ ព្រោះចង់បានផ្លែធំ និងកាត់បន្ថយការបំផ្លាញដោយសារខ្យល់ ។ |
| ២ | ដើមឈើសំណង់ដាំលាយជាមួយដំណាំកសិកម្ម,ដាំនៅតាមព្រំប្រទល់ចំការដំណាំ និង នៅជុំវិញត្រពាំង | *កន្ទ្បោមស្លឹក:* តូច បើកចំហបង្គួរ មិនសូវមានមែកកែងនឹងដើម ។<br>*ដើម:* ត្រង់ស្រឡូន មានរាងមូលដូចស៊ីឡាំង វែង ។<br>*របៀបចាក់ឫស:* ឫសចាក់ ជ្រៅ, ឫសចំហៀងចាក់ជ្រៅទៅក្នុងដីពី ២-៤ ហ្វីត ។ | នេះគឺជាលក្ខណៈសម្បត្តិនៃ កសិរុក្ខកម្ម សំរាប់តំបន់ណាដែលមានផ្ទៃដីបង្កបង្កើនផលតូចៗ ហើយត្រូវដាំដំណាំឆ្លាស់ចំរុះប្រភេទ ។ |
| ៣ | ដើមឈើហូបផ្លែដាំនៅក្នុងចំការដំណាំ | *កន្ទ្បោមស្លឹក:* តូច មែកតិចតួច<br>*ដើម:* អង្កត់ផ្ចិតតូច ។<br>*របៀបចាក់ឫស:* ឫសចំហៀងចាក់ជ្រៅទៅក្នុងដីពីជំរៅមិនតិចជាង ១-៣ ហ្វីត ។<br>*របៀបចេញផ្លែផ្កា:* ផ្លែជាប់នឹង មែក ។ | ភាពចុះសំរុងគ្នានៃប្រភេទដំណាំផ្សេងៗគឺជាចំណុចសំខាន់ផ្តល់ភាពងាយស្រួលក្នុងការដើរចេញចូល មិនរំខានទិដ្ឋា លេងកំសាន្តរបស់ក្មេងៗ ។ ចំណុចមួយទៀតគឺផ្លែនៅនឹងមែកខ្ពស់ផុតពីដៃអាចការពារពីក្មេងៗ និងសត្វ ពាហនៈ ។ |
| ៤ | ដើមឈើហូបផ្លែដាំនៅក្នុងចំការដំណាំ,តាមមាត់ត្រពាំង និងដាំលាយជាមួយដំណាំកសិកម្ម, | *កន្ទ្បោមស្លឹក:* ក្រាស់ មានមែកច្រើន ទាំងមែកកែងនឹងដើម និងមែកបញ្ឈរ ។<br>*ដើម:* ត្រង់ស្រឡូន មានរាងមូល ។<br>*ឫស:* ឫសចាក់ជ្រៅ,ឫសចំហៀងចាក់ជ្រៅទៅក្នុងដីពីជំរៅមិនតិចជាង ១-៣ ហ្វីត ។<br>*ផ្លែផ្កា:* ផ្លែជាប់នឹងមែក និងដើម ។ | ការដាំដើមឈើតាមរបៀបនេះគឺជារបៀបគំរូនៃចំការដំណាំ ។ គេច្រើនអនុវត្តនៅតំបន់ណាដែលមានផ្ទៃដីមិនសូវចង្អៀត និងសំរាប់គោលបំណងផលិតផ្លែឈើឱ្យបានច្រើនជាសំខាន់ ដោយមានឬមិនមានដាំដំណាំឆ្លះជាមួយ ។ |

ប្រភព: John ២០០១ ។ របាយការស្តីពីការការខិតខំនាអតីតកាលក្នុងការរៀបចំវិធីសាស្រ្តនៃការវាយតំលៃអំពីការចូលរួមពីមូលដ្ឋានសំរាប់កម្មវិធីរុក្ខសុវុឌ្ឍិការដោយមានការចូលរួម នៅអាស៊ី ។